**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខៈ ៧៨៥ អយក.គល.ទន

# សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ
## ការផ្គត់ផ្គង់សៀវភៅសិក្សាគោលភាសាបារាំងសម្រាប់ប្រើប្រាស់
## ក្នុងកម្មវិធីថ្នាក់ពីរភាសា បារាំង-ខ្មែរ ថវិកាកម្មវិធីឆ្នាំ២០១៨ ផ្នែកអប់រំ ជំពូក៦០
## គណនី៦០០២ អនុគណនី៦០០២២ កម្មវិធីទី៥ អនុកម្មវិធីទី៣ ចង្កោមសកម្មភាពទី១
## របស់អង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុ

ក្រសួងអប់រំ យុវជន និងកីឡា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ក្រសួងអប់រំ យុវជន និងកីឡា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់សៀវភៅសិក្សាគោលភាសាបារាំងសម្រាប់ប្រើប្រាស់ក្នុងកម្មវិធីថ្នាក់ពីរភាសា បារាំង-ខ្មែរ ថវិកាកម្មវិធីឆ្នាំ២០១៨ ផ្នែកអប់រំ ជំពូក៦០ គណនី៦០០២ អនុគណនី៦០០២២ កម្មវិធីទី៥ អនុកម្មវិធីទី៣ ចង្កោមសកម្មភាពទី១ របស់អង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុ ។

កិច្ចលទ្ធកម្មនេះនឹងត្រូវបានធ្វើឡើង តាមរយៈវិធីសាស្ត្រការដេញថ្លៃប្រកួតប្រជែងក្នុងស្រុក ក្រោមច្បាប់ និងស្របតាមបទបញ្ញត្តិលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃក្រសួងអប់រំ យុវជន និងកីឡា ដែលមានអាសយដ្ឋានអគាររដ្ឋបាលថ្មី(សាលាបឋមសិក្សាចៅពញាហុក)ជាន់ទីពីរ ផ្លូវលេខ៣៨០ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ៖ ០២៣ ២១០ ៤៦៤ / ០២៣ ២២០ ៩២៧ ទូរស័ព្ទ/ទូរសារលេខ៖០២៣ ២១៥ ២០២ អ៊ីមែល: procurement@moeys.gov.kh គេហទំព័រ www.moeys.gov. kh/procurement ចាប់ពីថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ ។

អ្នកដេញថ្លៃត្រូវកក់ប្រាក់ធានាការដេញថ្លៃ ដែលមានទឹកប្រាក់ចំនួន ៤ ៨០០ ០០០រៀល ( **បួនលាន ប្រាំបីរយពាន់រៀលគត់**) ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬធនាគារពាណិជ្ជដៃគូរណាមួយដែលបានចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅវេលាម៉ោង ០២:៣០ រសៀល ថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៨។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើនៅវេលាម៉ោង ០២:៣០ នាទីរសៀល ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយ ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃសូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១៨
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ- កាលប្បវត្តិ